# Medi-Cal
# មានធានារ៉ាប់រងមាត់ធ្មេញ

ក្នុងនាមជាសមាជិក **Medi-Cal** អត្ថប្រយោជន៍របស់អ្នក និងអត្ថប្រយោជន៍របស់កូនអ្នករួមបញ្ចូលទាំងការធានារ៉ាប់រងមាត់ធ្មេញផងដែរ។ សូមមើលគំនូសតាងខាងក្រោមសម្រាប់ទិដ្ឋភាពទូទៅនៃការថែទាំមាត់ធ្មេញដែលផ្តល់ការធានារ៉ាប់រងដោយ **Medi-Cal**។



| សេវាកម្ម | ទារក | កុមារ | មនុស្សវ័យជំទង់ | ស្ត្រីមានផ្ទៃពោះ | មនុស្សពេញវ័យ | មនុស្សវ័យចំណាស់ |
|---|---|---|---|---|---|---|
| ការពិនិត្យ* | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| កាំរស្មីអ៊ិច | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| ការសម្អាតធ្មេញ | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| ការលាបហ្វ្លអរីដ | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| ការប៉ះធ្មេញ | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| ការដកធ្មេញ | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| សេវាសង្គ្រោះបន្ទាន់ | ✹ | ✹ | ✹ | ✹ | ✹ | ✹ |
| ការប្រើថ្នាំបំបាត់ការឈឺចាប់ | ✹ | ✹ | ✹ | | ✹ | ✹ |
| អង្គធាតុប្រើសម្រាប់កុំអោយជ្រាបទឹកសម្រាប់ធ្មេញថ្គាម** | | ✹ | ✹ | | | |
| ការព្យាបាលធ្មេញពុកខ្លាំង | | ✹ | ✹ | ✹ | ✹ | ✹ |
| ការពត់តម្រង់ធ្មេញ (ការពាក់ដែកលើធ្មេញ)*** | | | ✹ | | | |
| ការស្រោបធ្មេញ | | | ✹ | ✹ | ✹ | ✹ |
| ក្រាសធ្មេញដោយផ្នែក និងទាំងមូល | | | ✹ | ✹ | ✹ | ✹ |
| ការដាក់ទ្រនាប់ក្រាសធ្មេញ | | | ✹ | ✹ | ✹ | ✹ |
| ការសម្អាតស៊ីជម្រៅក្រោមអញ្ចាញធ្មេញ | | | ✹ | ✹ | ✹ | ✹ |

*ការពិនិត្យសុខភាពធ្មេញដោយឥតគិតថ្លៃ ឬដោយតម្លៃទាបរៀងរាល់ប្រាំមួយខែម្តងសម្រាប់សមាជិកអាយុក្រោម 21 ឆ្នាំ រៀងរាល់ 12 ខែសម្រាប់សមាជិកដែលមានអាយុលើសពី 21 ឆ្នាំ។*
***មានធានារ៉ាប់រងលើអង្គធាតុប្រើសម្រាប់កុំអោយជ្រាបទឹកសម្រាប់ធ្មេញថ្គាមត្រូវបានគ្របដណ្តប់សម្រាប់មនុស្សវ័យជំទង់ដែលមានអាយុ 21 ឆ្នាំ។*
***សម្រាប់អ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល។*

## ទារក

ការជួបពិនិត្យធ្មេញដំបូងរបស់កូនអ្នកគួរតែធ្វើឡើងបន្ទាប់ពីធ្មេញដំបូងរបស់ពួកគេដុះឡើង ប៉ុន្តែមិនឱ្យលើសពីខួបកំណើតលើកដំបូងរបស់ពួកគេឡើយ។ ធ្មេញទារកមានសារៈសំខាន់ណាស់ចំពោះសុខភាព និងការអភិវឌ្ឍរបស់កូនអ្នក។ ធ្មេញទារកជួយគាត់ទំពារ និយាយ និងញញឹម។

## កុមារ

កុមារចាប់ផ្តើមបាត់បង់ធ្មេញទារកនៅដើមអាយុប្រាំឆ្នាំ។ ពោលគឺនៅពេលដែលធ្មេញអចិន្ត្រៃយ៍របស់ពួកគេចាប់ផ្តើមលូតលាស់។ សួរទន្តពេទ្យរកអង្គធាតុប្រើសម្រាប់កុំអោយជ្រាបទឹកសម្រាប់ធ្មេញថ្គាមដើម្បីជួយធ្មេញថ្គាមរបស់កូនអ្នកពីដង្កូវស៊ីធ្មេញ។

## មនុស្សវ័យជំទង់

ការញ៉ាំអាហារ និងភេសជ្ជៈដែលមានជាតិស្ករ ដូចដែលមនុស្សវ័យជំទង់ញ៉ាំជាញឹកញាប់ធ្វើឱ្យពួកគេប្រឈមនឹងហានិភ័យនៃជំងឺអញ្ចាញធ្មេញ និងការពុកធ្មេញ។ មនុស្សវ័យជំទង់ដែលបន្តទទួលការពិនិត្យសុខភាពមាត់ធ្មេញជាទៀងទាត់ធានាបាននូវសុខភាពមាត់ធ្មេញល្អដល់ពេញពួកគេពេញវ័យពេញ។

## ស្ត្រីមានផ្ទៃពោះ

ការថែទាំសុខភាពមាត់ធ្មេញល្អជួយទប់ស្កាត់បញ្ហាក្នុងពេលមានផ្ទៃពោះ។ ក្នុងនាមជាសមាជិក Medi-Cal អ្នកមានធានារ៉ាប់រងនៅពេលមានផ្ទៃពោះ និង 60 ថ្ងៃមុនពេលសំរាលកូនរបស់អ្នក។ ពេលវេលាដ៏ល្អបំផុតដើម្បីទៅជួបពេទ្យធ្មេញគឺនៅត្រីមាសទីពីររបស់អ្នក (សប្តាហ៍ទី 13 រហូតដល់សប្តាហ៍ទី 27 នៃការមានផ្ទៃពោះ) ។

## មនុស្សពេញវ័យ

គិតត្រឹមថ្ងៃទី 1 ខែមករា ឆ្នាំ 2018 ក្រសួងសេវាថែទាំសុខភាព (DHCS) បានស្តារឡើងវិញនូវអត្ថប្រយោជន៍ធ្មេញមនុស្សពេញវ័យសម្រាប់សមាជិកអាយុចាប់ពី 21 ឆ្នាំឡើងទៅជាមួយនឹងការធានារ៉ាប់រងធ្មេញពេញលេញ។ សម្រាប់បញ្ជីពេញលេញនៃសេវាកម្មដែលមានការធានារ៉ាប់រង សូមចូលមើល **SmileCalifornia.org**។

## មនុស្សវ័យចំណាស់

ក្នុងនាមជាមនុស្សពេញវ័យដែលមានវ័យចំណាស់ អ្នកងាយនឹងមានជំងឺអញ្ចាញធ្មេញនិងបញ្ហាសុខភាពមាត់ធ្មេញដទៃទៀត ប៉ុន្តែជាមួយនឹងការដុសពីរដងក្នុងមួយថ្ងៃការចាក់ធ្មេញប្រចាំថ្ងៃ ហើយអ្វីដែលសំខាន់បំផុតនោះគឺការទៅជួបទន្តពេទ្យរបស់អ្នកជាទៀងទាត់ អ្នកអាចកាត់បន្ថយហានិភ័យរបស់អ្នក

ស្វែងយល់អំពីអត្ថប្រយោជន៍មាត់ធ្មេញរបស់អ្នក និងរកទន្តពេទ្យ Medi-Cal នៅជិតអ្នកតាម **SmileCalifornia.org** ឬដោយទូរស័ព្ទមក **1-800-322-6384**។ ជាមួយនឹង Medi-Cal Dental ការជួបពិគ្រោះរបស់អ្នកគឺឥតគិត ឬដោយតម្លៃទាប។ កំណត់ពេលណាត់ជួបរបស់អ្នកនៅថ្ងៃនេះ!

**SmileCalifornia.org | 1-800-322-6384**

smile, CALIFORNIA™
MEDI-CAL HAS DENTAL COVERED